**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**

លេខ ៤៧៥-៩៦.សរណ

## ប្រធានតុលាការកំពូល

**ជម្រាបមក**

**លោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង**

**សូមជ្រាប។**

**កម្មវត្ថុ:** អំពីចំណាត់ការប្រគល់លិខិតផ្សេងៗ និងដីកាកោះរបស់តុលាការកំពូល ។

ខ្ញុំសូមជម្រាបលោកថា តុលាការកំពូលបានកត់សម្គាល់ឃើញថា តុលាការគ្រប់ខេត្ត-ក្រុង បានយកចិត្តទុកដាក់ច្រើនហើយ ប៉ុន្តែនៅមានការយឺតយ៉ាវក្នុងការប្រគល់លិខិតផ្សេងៗ និងដីកាកោះឱ្យដល់សាមីខ្លួន ពិសេសគឺការបង្វិលដើមលិខិតមកតុលាការកំពូលពុំបានមុខថ្ងៃណាត់ ដូច្នេះដើម្បីពង្រឹងការអនុវត្តច្បាប់ឱ្យកាន់តែមានប្រសិទ្ធិភាពខ្ពស់តុលាការកំពូលសុំឱ្យលោកប្រធានតុលាការគ្រប់ខេត្ត-ក្រុង ខិតខំយកចិត្តទុកដាក់ចាត់ការឱ្យប្រគល់លិខិតផ្សេងៗនិងដីកាកោះឱ្យដល់សាមីខ្លួន រួចបង្វិលដើមលិខិត និងដើមដីកាមកតុលាការកំពូលវិញ ឱ្យបានមុនថ្ងៃណាត់ ។

តុលាការកំពូលសង្ឃឹមថា អស់លោកច្បាស់ជាយកចិត្តទុកដាក់ជួយបំពេញភារកិច្ចនេះឱ្យបានត្រឹមត្រូវនិងយ៉ាងឆាប់រហ័ស តាមសំណូមពរនេះជាពុំខាន ។

ធ្វើនៅភ្នំពេញ ថ្ងៃទី០២ ខែតុលា ឆ្នាំ១៩៩៦

**ប្រធានតុលាការកំពូល**

**ចាន់ សុខ**

ចម្លងជូន

-ក្រសួងយុត្តិធម៌

-ដើម្បីជូនជ្រាប